# ការថែទាំកូនជ្រូក កំពុងផ្តាច់ដោះ



រៀបរៀងឡើងដោយគណៈកម្មការផលិតកម្ម និងបសុព្យាបាលខេត្តបន្ទាយមានជ័យ
ឧបត្ថម្ភដោយអង្គការ យូអិនឌីភី/យូអិនអូភីអេស/ឃែរ៉េរ៉េ (UNDP/UNOPS/CARERE)
ថតចម្លងលើកទីមួយ; ឆ្នាំ 1997

# ការថែទាំកូនជ្រូកបៅដោះ

## មាតិការឿង

① អាការៈមេជ្រូកមុនពេលកើតកូន..........1

បណ្តាអាការៈបង្ហាញឡើងពេលមេជ្រូកជិតកើតកូន..........1

② ការថែទាំកូនជ្រូកទើបនឹងកើត..........2

③ ផ្តល់កំដៅអោយកូនជ្រូក..........4

④ អោយកូនជ្រូកបៅដោះ..........5

⑤ បន្ថែមជាតិដែកអោយកូនជ្រូក..........11

⑥ ការផ្តាច់ដោះកូនជ្រូក..........12

⑦ ក្រៀវកូនជ្រូក និងចាក់ថ្នាំការពារអោយកូនជ្រូក..........13

⑧ បណ្តាមូលហេតុបង្កនូវភាពរាគរូសទៅលើកូនជ្រូក និងការដោះស្រាយ......13

⑨ តម្រូវការអំពីទ្រុង..........15

** ឯកសារយោង..........16

** ឈ្មោះគណៈកម្មការផលិតកម្ម និងបសុព្យាបាលខេត្តតំបន់ដាយ័ក្យ

# អារម្ភកថា

បើនិយាយអំពីការចិញ្ចឹមជ្រូកប្រជាពលរដ្ឋកម្ពុជាយើង មានប្រពៃណីចិញ្ចឹមតាំងពីយូរលង់ណាស់មកហើយ ។ រហូតមកដល់សព្វថ្ងៃនេះ ប្រពៃណីចិញ្ចឹមនេះនៅតែប្រកាន់ខ្ជាប់នៅតាមគ្រួសារកសិករ ។ គ្រួសារកសិករភាគច្រើននៅតាមជនបទរហូតដល់ជាយទីក្រុងមានចិញ្ចឹមជ្រូក គិតជាមធ្យមពី 2-5 ក្បាល មួយក្នុងគ្រួសារ ។ ប៉ុន្តែការចិញ្ចឹមនេះនៅមានលក្ខណៈជាយថាផលនៅឡើយគឺចិញ្ចឹមបានប៉ុណ្ណាយកប៉ុណ្ណោះ ។

ឈានចូលដល់សម័យវិទ្យាសាស្ត្របច្ចេកទេសជឿនលឿន ការចិញ្ចឹមសត្វគេត្រូវចិញ្ចឹមទៅតាមបែបផែនបច្ចេកទេស គេត្រូវធ្វើការគណនាប៉ាន់ប្រមាណអំពីផលចំណេញទុកជាមុន ។ ដើម្បីមានចំណេះដឹងគេត្រូវយល់ដឹងអំពីបច្ចេកទេសការចិញ្ចឹមអោយបានសមស្របជាទីបំផុត ។

ដើម្បីរួមចំណែកនូវចំណេះស្រាយសំណួរខាងលើ យើងខ្ញុំនិងចងក្រងសៀវភៅតូចនេះឡើងអំពីបច្ចេកទេសការថែទាំកូនជ្រូកកំពុងបៅដោះ សំរាប់ទុកធ្វើការផ្សព្វផ្សាយដល់ប្រជាកសិករនៅខេត្តតំបន់ដាច់ស្រយាលនៃព្រះរាជាណាចក្រកម្ពុជាយើង ហើយដែលកន្លងមកបច្ចេកទេសនេះបានអនុវត្តន៍នៅទីរួមខេត្តបន្ទាយមានជ័យ ហើយទទួលបាននូវលទ្ធផលខ្ពស់គួរអោយចាប់អារម្មណ៍ ។

ការថែទាំកូនជ្រូកកំពុងបៅដោះគឺជាបញ្ហាស្មុគ្រស្មាញ ដែលអ្នកចិញ្ចឹមជ្រូកភាគច្រើនតែងជួបប្រទះដូចជា : កូនជ្រូកកើតជំងឺរាគរូស លាមកពណ៌ស លឿង ប្រផេះ ហើមពោះ បាក់កម្លាំង ច្រមុះស្រទាប ក្រិន ចិញ្ចឹមក្រធំ ។ល។ បញ្ហាទាំងនេះនិងអាចដោះ-

ស្រាយបានលុះណាតែអ្នកចិញ្ចឹមអនុវត្តន៍អោយបានត្រឹមត្រូវ និងដំណាក់កាលរីកលូត-លាស់របស់កូនជ្រូកត្រូវធ្វើយ៉ាងណាខ្លះ ? កូនជ្រូកត្រូវការអ្វីខ្លះ ? ដើម្បីចិញ្ចឹមជីវិតអោយបានធំធាត់ និងពោរពេញទៅដោយសុខភាព ។

យើងខ្ញុំសង្ឃឹមថាសៀវភៅដ៏ស្តើងនេះ ចាត់ទុកជាការបង្កើតបច្ចេកទេសដែលមានផលប្រយោជន៍ ហើយផ្សារភ្ជាប់យ៉ាងជិតស្និទ្ធនិងអ្នកចិញ្ចឹមជ្រូក ។

គណៈកម្មការយើងខ្ញុំសង្ឃឹមថា និងទទួលបាននូវមតិយោបល់រួមចំណែកជាច្រើនរបស់មិត្តអ្នកអាន ដើម្បីកែលំអរសៀវភៅនេះពីមួយថ្ងៃទៅមួយថ្ងៃកាន់តែប្រសើរឡើង ។

គណៈកម្មការអភិវឌ្ឍន៍វិស័យផលិតកម្ម
និង បសុព្យាបាលខេត្តតំបន់ពាយ័ព្យ

# ការថែទាំកូនជ្រូកបៅដោះ

## ❶ អាការៈមេជ្រូកមុនពេលកើតកូន

រយៈពេលផើមរបស់ជ្រូកគឺ 114-115 ថ្ងៃ (3 ខែ 3 អាទិត្យ 3 ថ្ងៃ) ។ ថ្ងៃកើតកូនមានការប្រែប្រួល 1-2 ថ្ងៃ (អាចរហ័សជាង ឬយឺតជាង 1-2 ថ្ងៃ) ករណីពិសេសមានមេជ្រូកកើតកូនយឺតរហូតដល់ 7-10 ថ្ងៃ ។

*បណ្តាអាការៈបង្ហាញឡើងពេលមេជ្រូកជិតកើតកូន :*

ដើរចុះឡើងយ៉ាងពិបាក ដំណើរត្រឹមត្រូម កន្សោមដោះឡើង តឹងមានពណ៌ក្រហមស្រស់ យកដៃច្បូតមានចេញទឹកដោះ ។ មេជ្រូកកាច់សំបុក ឈ្ងុសស្នូក ឈ្ងួសទ្រុង ចុះអាចម៍បន្តបន្ទាប់ ឈាមករឹងប៉ុនៗម្រាមដៃ ។ ពេលបែកទឹកភ្លោះហូរចេញមក (ទឹករំអិលខាប់អន្ទិល ឬមានអាចម៍ព្រៃរបស់កូនជ្រូកហូរចេញមកជាមួយ) គឺជាពេលកូនជ្រូកជិតកើតចេញមក ។ មេជ្រូកកូនដំបូង (កូនលើកទីមួយ) ច្រើនកើតពិបាកជាងមេជ្រូកចាស់ (សំរាលកូនលើសពី 2 ដងឡើងទៅ) ជាធម្មតាគឺរាល់ក្រោយពេលប្រឹងយ៉ាងខ្លាំងម្តងៗ មេជ្រូករួញកន្ទ្រាក់ជើងក្រោយឡើង គឺពេលនោះដែលកូនជ្រូកត្រូវបានមេប្រឹងជំរុញចេញមកក្រៅ ធម្មតាជាមធ្យមពី 10-15 នាទី 15 នាទី ទៅមួយម៉ោង មេជ្រូកបង្កើតបានកូនមួយក្បាល ។ មានករណីមេជ្រូកកើតបន្តបន្ទាប់ 2-3 ក្បាល ក្នុងរង្វង់ 10 នាទី ។ បើសិនមេជ្រូកបង្កើតកូនស្រួលគ្រាន់តែក្រោយ 2-5 ម៉ោង គឺបង្កើតកូនរួច និងក្រោយ 2-3 ម៉ោង សុកនឹងធ្លាក់ចេញមករសំ ។

ក្នុងពេលដែលកូនជ្រូកកើតចេញពីពោះមេ អាចក្បាលកើតចេញមកមុន ឬជើងក្រោយពីចេញមកមុន កើតមកបន្តបន្ទាប់គ្មានអ្វីជាគ្រោះថ្នាក់ទេ ។ ប៉ុន្តែក្នុងករណីដែលមេជ្រូកបានបែកទឹកភ្លោះ 3-6 ម៉ោង ហើយមិនឃើញកូនជ្រូកកើតចេញមកត្រូវតែទៅរកអ្នកបច្ចេកទេស បសុពេទ្យមកធ្វើអន្តរាគមន៍ ។

❷ <u>ការថែទាំកូនជ្រូកទើបនឹងកើត</u>

ពេលកូនជ្រូកកើតចេញមកពីពោះមេ អាចកើតក្បាលចេញមកមុន ឬជើងក្រោយ 2 ចេញមកមុន ។ នៅក្នុងពោះមេកូនជ្រូកទំលាយស្រោមសុកដោយខ្លួនវា និងកើតចេញមកក្រៅ ។ ករណីខ្លះកូនជ្រូកកើតមកទាំងស្រោម យើងចាំបាច់ប្រញាប់ប្រញាល់ហែកទំលាយស្រោម ដើម្បីយកកូនចេញមកកុំអោយកូនជ្រូកថប់ដង្ហើម ។

កូនជ្រូកកើតមកភ្លាមប្រឡាក់ប្រឡូសដោយទឹករំអិល យើងត្រូវចាប់លើកកូនជ្រូកម្តងៗ យកកន្សែងស្អាតមកជូតជំរះទឹករំអិលក្នុងមាត់ ច្រមុះ និងខ្លួនអោយបានស្អាត ប្រើសសៃអំបោះត្រាំក្នុងអាល់កុលចុងទងផ្ចិត ចន្លោះពីពោះ 3 សង្ទីម៉ែត្រួចហើយយកកន្ត្រៃស្អាត (ជូតជំរះដោយអាល់កុល) កាត់ទងផ្ចិតឃ្លាតពីចំណុចចង 2 សង្ទីម៉ែត្រ ជូតសំអាតកន្លែងកាត់ដោយថ្នាំក្រហម ឬអាល់កុលអ៊ីយ៉ូត ប្រើកន្ត្រៃកាត់ក្រចក ឬកន្ត្រៃសំរាប់កាត់ធ្មេញ កាត់ធ្មេញស្រួចទាំង 8 របស់កូនជ្រូក (ធ្មេញ 4 ខាងលើ ធ្មេញ 4 ខាងក្រោម) កាត់យកចេញផ្នែកស្រួចពីរភាគបីនៃធ្មេញធ្វើយ៉ាងណាកុំអោយមុតឬសអញ្ចាញធ្មេញ ។ ការកាត់ធ្មេញកាន់តែរហ័សគឺកាន់តែល្អ (កុំអោយលើសពី 24 ម៉ោង ក្រោយពេលកើត) ពីព្រោះពេលនោះធ្មេញនៅទន់ ឈាមហូរតិច ។ ផលប្រយោជន៍នៃការកាត់ធ្មេញ ដើម្បីជៀសវាងកុំអោយកូនជ្រូកខាំដោះមេវា និងខាំផណ្តើមគ្នានៅពេលដែលវាបៅដោះមេរបស់វា ។